**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ៖ ៣៩៥ ហគ.កបទ.សអ

## សេចក្តីជូនដំណឹង

## ស្តីពីការដេញថ្លៃការផ្គត់ផ្គង់ប្រេងឥន្ធនៈ ឆមាសទី១ ឆ្នាំ២០២៣

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន ឬ សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ជ្រាបថា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈនូវការផ្គត់ផ្គង់ប្រេងឥន្ធនៈ ឆមាសទី១ ឆ្នាំ២០២៣ សម្រាប់គណៈកម្មាធិការជាតិអេស្កាប់ ដូចមានព័ត៌មានខាងក្រោម៖

- ឯកសារសម្រាប់ការចូលរួមដេញថ្លៃមានផ្តល់ជូន នៅអង្គភាពលទ្ធកម្មទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាសយដ្ឋានលេខ៣ វិថីសម្តេចហ៊ុនសែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៣ រហូតដល់ថ្ងៃឈប់ទទួលពាក្យនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ០៩:០០ នាទីព្រឹកជាកំហិត
- ការបើកឯកសារដេញថ្លៃជាផ្លូវការ នឹងប្រព្រឹត្តទៅនៅវេលាម៉ោង ០៩:០០នាទីព្រឹក នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ នៅអាសយដ្ឋានខាងលើដដែល
- ក្រុមហ៊ុន ឬសហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអង្គភាពលទ្ធកម្ម នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមអាសយដ្ឋានខាងលើនេះរៀងរាល់ម៉ោងធ្វើការ៕

ថ្ងៃ ព្រហ ៣កើត ខែ ផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០២៣

**ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**អនុប្រធាន**

**ញឹម ខេមរា**

**ចម្លងជូន៖**
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- ឯកសារ កាលប្បវត្តិ


អាសយដ្ឋាន៖ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh